THE WORLD BANK
IBRD • IDA | WORLD BANK GROUP

**សេចក្ដីប្រកាសព័ត៌មាន**

# ប្រើប្រាស់ម៉ោងបង្រៀនឱ្យអស់លទ្ធភាព និងកែលម្អការបង្រៀន ដើម្បីបង្កើនគុណភាពនៃការរៀននៅកម្ពុជា

**ភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥** — ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការបញ្ជូនកុមារឱ្យចូលរៀន ប៉ុន្តែពេលនេះចាំបាច់ត្រូវកែលម្អជាបន្ទាន់នូវសកម្មភាពគ្រប់បែបយ៉ាងដែលកើតឡើងនៅក្នុងថ្នាក់រៀន។ របាយការណ៍ថ្មីពីរដែលធនាគារពិភពលោកបានចេញផ្សាយនៅថ្ងៃនេះ បាននិយាយដូច្នេះ ដោយសង្កត់ធ្ងន់លើការពិនិត្យមើលទាំងគុណភាព និងបរិមាណនៃការបង្រៀននៅតាមសាលាបឋមសិក្សា ហើយបានលើកអនុសាសន៍មួយចំនួនសម្រាប់ពង្រឹងអក្ខរកម្ម និងលេខនព្វន្តជាមូលដ្ឋាន ដើម្បីឱ្យកុមារទាំងអស់មានមូលដ្ឋានគ្រឹះក្នុងការរៀនសូត្រចេះ និងរីកចម្រើនទៅមុខទៀត។

**លោកស្រី Tania Meyer នាយិកាគ្រប់គ្រងនៃធនាគារពិភពលោកប្រចាំកម្ពុជា** មានប្រសាសន៍ថា៖ « *តាមរយៈការវិនិយោគលើគ្រូបង្រៀន និងការបង្កើនម៉ោងសិក្សា កម្ពុជាអាចផ្ដល់ឱកាសឱ្យកុមារទទួលបានការអប់រំកាន់តែប្រសើរឡើង ដើម្បីក្លាយខ្លួនជាកម្លាំងពលកម្មមួយដែលមានភាពប្រកួតប្រជែងជាងមុនផងដែរ»។* លោកស្រីបានបន្ថែមទៀតថា៖ *«ធនាគារពិភពលោកប្ដេជ្ញាចិត្តក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកែលម្អការរៀនសូត្រ និងបង្កើតឱកាសសម្រាប់កុមារគ្រប់រូប ហើយតាមរយៈនេះ ត្រួសត្រាយផ្លូវសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងការងារកាន់តែប្រសើរ ទៅពេលអនាគត»។*

របាយការណ៍មួយក្រោមចំណងជើងថា **«គុណភាពគ្រូបង្រៀនក្នុងការអប់រំបឋមសិក្សានៅកម្ពុជា៖ ឆ្ពោះទៅរកការលើកទឹកចិត្តចំពោះកិច្ចខិតខំប្រឹងប្រែង, សមិទ្ធកម្មការងារ និងការធានាគុណភាព»** ***(Teacher Quality in Cambodia's Primary Education: Toward Incentivizing Effort, Performance, and Quality Assurance)*** បង្ហាញថា ចាំបាច់ត្រូវមានកិច្ចខិតខំថែមទៀត ក្នុងការពង្រឹងគុណភាពនៃការបង្រៀននៅតាមសាលា។ ទោះបីជាប្រាក់ខែគ្រូបង្រៀនកាន់តែខ្ពស់បានលើកទឹកចិត្តសិស្សដែលរៀនចប់វិទ្យាល័យជាមួយពិន្ទុល្អបំផុតឱ្យមកចូលរួមក្នុងវិជ្ជាជីវៈនេះ ក៏ពិតមែន ជាក់ស្ដែងនៅក្នុងថ្នាក់រៀន ការអនុវត្តការបង្រៀន ឬចំណេះដឹងមុខវិជ្ជា មិនទាន់មានការកែលម្អប្រសើរនៅឡើយទេ។ របាយការណ៍នេះកត់សម្គាល់ថា គ្រូបង្រៀនបឋមសិក្សាជាច្រើននៅតែបន្តធ្វើការងារក្រៅ  ដែលជាហេតុធ្វើឱ្យពួកគេនៅសល់ពេល និងថាមពលកាន់តែតិចតួចសម្រាប់បង្រៀនសិស្សរបស់ខ្លួន។

ដើម្បីកែលម្អលទ្ធផលសិក្សា របាយការណ៍នេះអំពាវនាវឱ្យបង្កើនការវិនិយោគលើការបណ្ដុះបណ្ដាលគ្រូបង្រៀនមុនចូលបម្រើការងារ និងក្នុងពេលបម្រើការងារ។ ជាមួយនឹងការរំពឹងទុកថានឹងមានគ្រូបង្រៀនថ្មីជាច្រើនចូលប្រឡូកនៅក្នុងវិជ្ជាជីវៈនេះក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ពេលនេះជាឱកាសមួយដើម្បីកសាងគ្រូបង្រៀនជំនាន់ថ្មីដែលមានគុណភាពខ្ពស់ហើយ។

របាយការណ៍មួយទៀតក្រោមចំណងជើង **«ម៉ោងបង្រៀន និងការរៀនរបស់សិស្ស៖ តើកម្ពុជាអាចកែលម្អលទ្ធផលសិក្សាបានដែរឬទេ តាមរយៈការដាក់ឱ្យដំណើរការកម្មវិធីសិក្សាពេញមួយថ្ងៃនៅសាលាបឋមសិក្សា?»** ***(Instruction Time and Student Learning: Can Cambodia Improve Learning Outcomes by Introducing Full-day Lesson Schedules in Primary Schools?)*** បានឱ្យដឹងថា បើទុកជាសាលារៀននៅកម្ពុជាបានចែកពេលក្នុងថ្នាក់រៀនយ៉ាងច្រើនរួចទៅហើយសម្រាប់មុខវិជ្ជាអក្ខរកម្ម និងលេខនព្វន្តក៏ដោយ ក៏សិស្សមួយចំនួនធំនៅតែត្រដាបត្រដួសក្នុងការរៀនជំនាញទាំងនេះ នៅឡើយ។

ផ្អែកលើបទពិសោធន៍អន្តរជាតិ របាយការណ៍នេះផ្តល់អនុសាសន៍ឱ្យចាត់វិធានការសន្សំសំចៃ ដើម្បីកែលម្អលទ្ធផល ដូចជាការកាត់បន្ថយអវត្តមានរបស់គ្រូ, ការកាត់បន្ថយការបិទសាលារៀនក្រៅពេលឈប់សម្រាកផ្លូវការ និងការបង្កើនចំនួនសប្តាហ៍បង្រៀនក្នុងឆ្នាំសិក្សា។ ក្នុងករណីដែលក្រសួងអប់រំ យុវជន និងកីឡា សម្រេចពង្រីកពេលការសិក្សាពេញមួយថ្ងៃ នៅកម្រិតបឋមសិក្សា របាយការណ៍នេះស្នើឱ្យប្រើវិធីសាស្ត្រជាជំហានៗក្នុងរយៈពេលវែង ដើម្បីធានាបានទាំងផលដែលចង់បាន និងលទ្ធភាពនៃការចំណាញ ផងដែរ។ របាយការណ៍ក៏សង្កត់ធ្ងន់ផងដែរលើតម្រូវការសម្រាប់ការវិនិយោគជាបន្តបន្ទាប់ ដើម្បីកែលម្អគុណភាព និងប្រសិទ្ធភាពនៃការបង្រៀនក្នុងថ្នាក់រៀន។

**សម្រាប់ទាក់ទង៖**

នៅភ្នំពេញ៖ ប៊ូ សារឿន, 855 12 414 088, sbou@worldbank.org

នៅទីក្រុងវ៉ាស៊ីនតោន៖ World Bank Media Relations: +1 (202) 473 7660, press@worldbank.org

For more information, please visit: www.worldbank.org/eap
Follow us on X: @WB_AsiaPacific
For our YouTube channel: www.youtube.com/worldbank

Press Release No. 2026/026/EAP